**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

********

**សាលាដំបូងរាជធានីភ្នំពេញ**

******

សាលក្រមព្រហ្មទណ្ឌលេខ: ១២៩ " ក្រ₂ វ"

ចុះថ្ងៃទី ១៧.០២.២០២០

សំណុំរឿងព្រហ្មទណ្ឌលេខ:៥៣៨៣

ចុះថ្ងៃទី ១២-០៨-២០១៩

ស៊ើបសួរលេខ: ៣៦៥៧

ចុះថ្ងៃទី ១៤.០៨.២០១៩

ដំណុំជម្រះលេខ: ៤១៩៧

ចុះថ្ងៃទី ០២.១១.២០១៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជំនុំជម្រះជាអសាធារណៈ នៅសាលសវនាការនៃសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ០៨ និង ៣០ នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចតទៅ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោកស្រីចៅក្រម [redacted]ប្រធានក្រុមប្រឹក្សា

-លោកស្រីអនុប្រធាន[redacted] ជាចៅក្រមប្រឹក្សា

-លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោកស្រី[redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-កញ្ញា [redacted] ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៥៣៨៣ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទឈ្មោះ [redacted] អ៊ុម ហៅ ហ្វា ភេទប្រុស អាយុ១៥ឆ្នាំ(កើតថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤) ជនជាតិខ្មែរ មុខរបរនេសាទ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូ[redacted] ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ឪពុកឈ្មោះ ភួ "ស" ម្តាយឈ្មោះ សាស្ត្រ "វ" នៅលីវ ទោសពីមុនគ្មាន ជាអនីតិជន។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៧៤០ "គ₁" ដ.ឃ.ដ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩។

ជាប់ចោទពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិ១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង ១៨ និង ០០ នាទី កម្លាំងសមត្ថកិច្ចនគរបាលខណ្ឌជ្រោយចង្វារ បានធ្វើការចុះបង្ក្រាបករណី ជួញដូរ និងប្រើប្រាស់គ្រឿងញៀន នៅក្រោយវិហារឯករង្សី ផ្លូវបេតុង ភូមិមួយ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ បានឃាត់ខ្លួនជនត្រូវចោទជាអ្នកជួញដូរគ្រឿងញៀនចំនួន ០១នាក់ ឈ្មោះ [redacted] អ៊ុម ភេទប្រុស អាយុ ១៥ឆ្នាំ និងអ្នកប្រើប្រាស់ថ្នាំញៀនចំនួន ០២នាក់ មានឈ្មោះ [redacted]វុត្ថា ភេទប្រុស អាយុ ៣៥ឆ្នាំ និង

ឈ្មោះ [redacted] សុភ័ក្រ ភេទប្រុស អាយុ ២៧ឆ្នាំ រួមទាំងវត្ថុតាងមួយចំនួនយកមកធ្វើការសាកសួរ នៅអធិការដ្ឋាននគរបាលខណ្ឌជ្រោយចង្វារ រួចសមត្ថកិច្ចបានបង្គស់សំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ:** របាយការណ៍សំយោគលេខ ០៨២/១៩ ន.ប.ក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌជ្រោយចង្វារ។

**-បានឃើញ:** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ៣៧០៧ អ.យ.ច ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ:** ដីកាសន្និដ្ឋានស្ថាពរលេខ: ៤១៨៤ អ.យ.ច ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ:** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ៥២៣៣ "គ១" ដ.ដ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] អ៊ឹម បានឆ្លើយថា: នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង ១២ និង៣០នាទីថ្ងៃត្រង់ ខ្លួនបានយកថ្នាំញៀនពីឈ្មោះ ញ៉ា ចំនួន ០១កញ្ចប់ ក្នុងតម្លៃ ៨០,០០០៛ (ប្រាំបីម៉ឺនរៀល) និងបានយកទៅរំលែកបានចំនួន ០៥កញ្ចប់ យកមកលក់នៅកន្លែងដដែល ពេលកំពុងតែលក់ថ្នាំឱ្យគេ ក៏មានសមត្ថកិច្ចមកចាប់ខ្លួនតែម្តង។ នៅពេលចាប់ខ្លួន សមត្ថកិច្ចបានដកហូតថ្នាំញៀនចំនួន ០៥កញ្ចប់តូច និងលុយ ៤៨,០០០៛ (បួនម៉ឺនប្រាំបីពាន់រៀល)។ ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀនអស់រយៈពេលមួយខែមកហើយ។ កន្លងមកខ្លួនធ្លាប់យកថ្នាំញៀនពីឈ្មោះ ញ៉ា ភេទប្រុស បានចំនួន ០៤ដង មកហើយ ដោយយកម្តង១មួយកញ្ចប់តម្លៃ ៨០,០០០៛ (ប្រាំបីម៉ឺនរៀល) យកមករំលែកសម្រាប់លក់បន្តក្នុងមួយកញ្ចប់តម្លៃ ១០,០០០៛ (មួយម៉ឺនរៀល) , ១៥,០០០៛ (មួយម៉ឺនប្រាំពាន់រៀល) និង ២០,០០០៛ (ពីរម៉ឺនរៀល) លក់នៅក្រោយវិហារឯករង្សី លក់អស់ទើបយកលុយ ៨០,០០០៛ (ប្រាំបីម៉ឺនរៀល) ទៅឱ្យឈ្មោះ ញ៉ា។ ខ្លួនយកថ្នាំញៀនមកលក់ គឺដោយសារឈ្មោះ ញ៉ា ជាអ្នកឱ្យថ្នាំមកខ្លួនដើម្បីយកមកលក់ ពេលលក់បានទើបឱ្យលុយទៅឈ្មោះ ញ៉ា ចំណេញប៉ុន្មានខ្លួនយកខ្លួនឯង។ ខ្លួនមិនស្គាល់សាវតាឈ្មោះ ញ៉ា ទេ គ្រាន់តែដឹងថាឈ្មោះនេះ មានផ្ទះនៅក្រោយវិហារឯករង្សី។ ខ្លួនទទួលស្គាល់កំហុស ពិតជាបានប្រព្រឹត្តដូចការចោទមែន និងសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង។

-សាក្សីឈ្មោះ [redacted] សារ៉ាត ជាមន្ត្រីនគរបាលយុត្តិធម៌ថា: ខ្លួនគឺជានាយផ្នែកអធិការដ្ឋាននគរបាលខណ្ឌជ្រោយចង្វារ ហើយនៅថ្ងៃកើតហេតុគឺក្រុមខ្លួនបានចុះប្រតិបត្តិការណ៍ដោយឃាត់ខ្លួនបានជនសង្ស័យម្នាក់ឈ្មោះ [redacted] អ៊ឹម ភេទប្រុស និងឆែកឆេរឃើញមានថ្នាំញៀនចំនួនប្រាំកញ្ចប់តូច និងបានឃាត់ខ្លួនជនសង្ស័យតែម្តង។ ជននេះជាមុខសញ្ញាក្នុងករណីជួញដូរគ្រឿងញៀន។

-កំណត់ហេតុទទួលវត្ថុចាប់យក(១)លេខ ២៤៧៩ វវត ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-ក្រឡាបញ្ជីអានលទ្ធផលកោសល្យវិច័យលេខ ២០៣០៤/១៩ ម.ព.អ.ជ.ប.គ.ញ និងលេខ ២០៣០៣/១៩ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] អ៊ឹម ភេទប្រុស អាយុ១៥ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិ១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៩ និងតម្កល់ដីកាសន្និដ្ឋានស្ពាពរទុកជាបានការដដែរ។ ដូចនេះ តំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] អ៊ឹម ភេទប្រុស ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងស្នើសុំឱ្យចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនល្មើសតាមច្បាប់។

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា: ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ដោយកូនក្តីខ្លួនឈ្មោះ [redacted] អ៊ឹម ជាអនីតិជន ហើយបានឆ្លើយសារភាពនៅគ្រប់ដំណាក់កាល ថាខ្លួនពិតជាទិញថ្នាំញៀនពីចំនួន ឈ្មោះ ញ៉ា ក្នុងតម្លៃ ៨០.០០០៛ និងយកទៅវែចកលក់ប្រាកចំណេញ។ ដោយសារកូនក្តីខ្លួនបានឆ្លើយសារភាពនៅគ្រប់ដំណាក់គប្បីស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាទៅលើមាត្រា ១៦០ ១៦៤ នៃក្រមព្រហ្មទណ្ឌ ។ ដូចនេះ ផ្អែកតាមអង្គហេតុ និងអនុលោមតាមបទប្បញ្ញត្តិជាធរមានខាងលើ ស្នើសុំឱ្យតុលាការមេត្តាពិចារណា និងសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] អ៊ឹម ហៅ ហ្វា ទទួលនូវស្ថានសម្រាល និងស្នើសុំដោះលែងភ្លាមៗដោយក្តីអនុគ្រោះ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] អ៊ឹម ថា: ចំពោះរឿងនេះ ខ្លួនស្នើសុំឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] អ៊ឹម

-ក្រោយពីបានស្តាប់ចម្លើយសាក្សីជាមន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ [redacted] សាវ៉ាត

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើភស្តុតាងឯកសារផ្សេងៗនៅក្នុងសំណុំរឿង

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ ៥៣៨៣ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ មកជំនុំជម្រះតាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ៥២៣៣ "គ១" ដ.ង ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ដែលមានជនជាប់ចោទឈ្មោះ [redacted] អ៊ឹម ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិ១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង ១៨ និង០០នាទី កម្លាំងអធិការដ្ឋាននគរបាលខណ្ឌជ្រោយចង្វារ បានឃាត់ជនសង្ស័យម្នាក់ឈ្មោះ [redacted] អ៊ឹម ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ ដោយដកហូតបានគ្រឿងញៀន/



Scanned with CamScanner

ចំនួន ៥ កញ្ចប់តូច ទម្ងន់ ០.២៤ក្រាម ត្រង់ចំណុចផ្លូវបេតុង ភូមិ១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រាកដមែន។

៣-ជនជាប់ចោទឈ្មោះ [redacted] អ៊ុម បានឆ្លើយថា: នៅថ្ងៃកើតហេតុ ខ្លួនបានយកថ្នាំញៀនទៅលក់នៅក្រោយវិហារឯករង្សី។ នៅពេលដែលកំពុងលក់ថ្នាំញៀនឱ្យបុរសម្នាក់ឈ្មោះ ថា ស្រាប់តែមានក្រុមសមត្ថកិច្ចមានគ្នាជាច្រើននាក់ បានចុះបង្ក្រាប ខណៈពេលដែលខ្លួនកំពុងតែលក់ថ្នាំញៀន រួចហើយបានឃាត់ខ្លួនខ្ញុំបាទតែម្តង។

៤-ផ្អែកតាមរបាយការណ៍សំយោគលេខ ០៨២/១៩ រ.ប.ក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌជ្រោយចង្វារ បានសន្និដ្ឋានថា ជនសង្ស័យឈ្មោះ [redacted] **អ៊ុម ភេទប្រុស អាយុ១៥ឆ្នាំ** ពិតជាបានប្រព្រឹត្តបទល្មើស **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិ១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៩ ប្រាកដមែន។

៥-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ២០៣០៣/១៩ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបង្ហាញថា សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន(ហៅក្រៅ អាយ ឬម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ៧០,៥៦% (ចិតសិប ក្បៀស ហាសិបប្រាំមួយ ភាគរយ) នៃទម្ងន់សរុបវាស្ថិតក្នុងតារាងទី២ មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៦-សារធាតុញៀនដែលចាប់យកពីជនជាប់ចោទឈ្មោះ [redacted] អ៊ុម ជាក្រាមពណ៌សថ្លាមានទម្ងន់សរុបចំនួន ០.២៤ ក្រាម ដែលជាសារធាតុមេតំហ្វេតាមីនមានកម្រិតភាពសុទ្ធចំនួន ៧០,៥៦% នៃទម្ងន់សរុប ដូចនេះបរិមាណសុទ្ធមេតំហ្វេតាមីនគឺ $\frac{70.56 \times 0.24}{100} = 0.16g$ ឃើញថាសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន មានបរិមាណភាពសុទ្ធចំនួន ០.១៦ (សូន្យក្បៀស ដប់ប្រាំមួយ) ក្រាម ដូចនេះបរិមាណសុទ្ធក្រោម ១៥ (ក្រាម) គឺស្ថិតនៅក្នុងមាត្រា ៤០ កថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៧- តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ២០៣០៤/១៩ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបង្ហាញថា សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន(ហៅក្រៅ អាយ ឬម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ៦៥.១៣% (ហុកសិបប្រាំ ក្បៀស ដប់បី ភាគរយ) នៃទម្ងន់សរុបវាស្ថិតក្នុងតារាងទី២ មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-សារធាតុញៀនដែលចាប់យកពីជនជាប់ចោទឈ្មោះ ញ៉ា(គេចខ្លួន) ជាក្រាមពណ៌សថ្លាមានទម្ងន់សរុបចំនួន ៤.០៥ ក្រាម ដែលជាសារធាតុមេតំហ្វេតាមីនមានកម្រិតភាពសុទ្ធចំនួន ៦៥.១៣% នៃទម្ងន់សរុប ដូចនេះបរិមាណសុទ្ធមេតំហ្វេតាមីនគឺ $\frac{65.13 \times 4.05}{100} = 2.63g$ ឃើញថាសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន មានបរិមាណភាពសុទ្ធចំនួន ២.៦៣ (ពីរក្បៀស ហុកសិបបី) ក្រាម ដូចនេះបរិមាណសុទ្ធក្រោម ១៥ (ក្រាម) គឺស្ថិតនៅក្នុងមាត្រា ៤០ កថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

Scanned with CamScanner

៩-សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] អ៊ីម ដែលបានទិញថ្នាំញៀនដើម្បីយកមកលក់ ហើយត្រូវបានសមត្ថកិច្ចឆែកឆេរឃើញមានថ្នាំញៀនចំនួនប្រាំកញ្ចប់ ត្រូវច្បាប់កំណត់ថាជាបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ហើយបញ្ញត្តិឱ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ៤.០០០.០០០(បួនលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១០-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: មានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទឈ្មោះ [redacted] អ៊ីម ភេទប្រុស ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១១-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថាដោយស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួនដែលបានឆ្លើយសារភាពរួចហើយ គប្បីតុលាការនឹងលើកយកមកពិចារណា។

១២-អំពើរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់សុខភាពផ្ទាល់ខ្លួនព្រមទាំងបាត់បង់នូវសតិស្មារតីដែលអាចបង្កនូវអំពើមិនស្របច្បាប់បណ្តាលឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈរបៀបរៀបរយល្អក្នុងសង្គមដែលច្បាប់ហាមឃាត់ជាពិសេសបានបំពានទៅនឹងមាត្រា ៤០ កថាខណ្ឌ៤ នៃច្បាប់ស្តីពីត្រួតពិនិត្យគ្រឿងញៀន។

១៣-ជនជាប់ចោទជាអនីតិជនមានស្មារតីគ្រប់គ្រាន់ដែលពុំមានភស្តុតាងណាមួយបញ្ជាក់ថាមានវិបល្លាសស្មារតីទេ ដូច្នេះជនជាប់ចោទត្រូវតែទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដែលបានប្រព្រឹត្ត។

១៤-ក្នុងពេលប្រព្រឹត្តបទល្មើសជនជាប់ចោទឈ្មោះ [redacted] អ៊ីម ភេទប្រុស អាយុ១៥ឆ្នាំ ជាអនីតិជន គប្បីតុលាការគិតពីស្ថានសម្រាលដល់ជនជាប់ចោទ ដោយផ្អែកតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

១៥-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] អ៊ីម ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ ពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិ១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៦-វត្ថុតាងចាប់យកមានដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ២៤៧៩ វវត ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ជាវត្ថុដែលពាក់ព័ន្ធនឹងបទល្មើស គប្បីសម្រេចរឹបអូសតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គឺមាន ១-ស្រោមសំបុត្របិតជិតពណ៌ស ដែលមានសរសេរថា ក្រាមពណ៌សថ្លាចេញពណ៌លឿងទុំសង្ស័យថាមានតម្រុយជាគ្រឿងញៀនប្រភេទមេតំហ្វាតាមីនទម្ងន់ ០.២៤ក្រាម របស់ឈ្មោះ ណា អ៊ីម និងក្រាមពណ៌សថ្លាសង្ស័យជាគ្រឿងញៀនមេតំហ្វេតាមីនទម្ងន់ ៤.០៥ក្រាមរបស់ឈ្មោះ ញ៉ា និងសំបកថង់ប្លាស្ទិកចំនួន២១ ដោយមានស្នាមផ្តិតមេដៃរបស់ជនសង្ស័យឈ្មោះ [redacted] អ៊ីម និងអ្នកចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ២-ទូរស័ព្ទដៃចំនួន០៦គ្រឿង ម៉ាក សាំងសុង ពណ៌ស ចំនួន០១គ្រឿង និងម៉ាកម៉ីហ្សុះ ពណ៌ទឹកប្រាក់ចំនួន០៥គ្រឿង(មិនដំណើរការ) និង៣-ដាវសាំម៉ូរ៉ៃចំនួន០២ដើម ចំពាមកៅស៊ូចំនួន០១ កូនថង់សម្រាប់ច្រកគ្រឿងញៀនមួយចំនួន ឧបករណ៍សម្រាប់ប្រើប្រាស់ថ្នាំញៀនមួយចំនួន ជញ្ជីងថ្លឹងថ្នាំញៀនចំនួន០១ជារបសឈ្មោះ ញ៉ា(គេចខ្លួន)។



Scanned with CamScanner

## ហេតុដូច្នេះ សម្រេច

១-ផ្តន្ទាទោសឈ្មោះ [redacted] អ៊ីម ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ មុខរបរនេសាទ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូ [redacted] ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ឪពុកឈ្មោះ ភូ "ស" ម្តាយឈ្មោះ សាស្ត្រ "វ" នៅលីវ ទោសពីមុនគ្មាន ជាអនីតិជន។

**ដាក់ពន្ធនាគារកំណត់ ១៨(ដប់ប្រាំបី)ខែ និងពិន័យជាប្រាក់ចំនួន ២.០០០.០០០(ពីរលាន) រៀល។**

ពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវបេតុង ភូមិ១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

២-រឹបអូសវត្ថុតាងមាន: ថ្នាំញៀនចំនួន ៤.២៩ក្រាម សំបកថង់ប្លាស្ទិកចំនួន២១ ទូរស័ព្ទដៃចំនួន០៦គ្រឿង ដែលមានម៉ាកសាំងសុងពណ៌សចំនួន០១គ្រឿង និងម៉ាកម៉ីហ្សុះ ពណ៌ទឹកប្រាក់ចំនួន៥គ្រឿង(មិនដំណើរការ) និងដាវសាំម៉ូរ៉ៃចំនួន០១ដើម ចំពាមកៅស៊ូចំនួន០១ ឧបករណ៍សម្រាប់ប្រើប្រាស់មួយចំនួន ជញ្ជីងថ្លឹងថ្នាំញៀនចំនួន០១។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ និងប្រកាសសាលក្រមជាអសាធារណៈនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] អ៊ីម។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា |

[redacted]

---

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ចន្ទ ៩កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner